ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ......០៧៦/២៣.....គ.ជ.ប.ជ

# របាយការណ៍ខែវិច្ឆិកា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែធ្នូ ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

សភាពការណ៍សាកលលោក មានការវិវត្តន៍ប្រែប្រួលថ្មីៗ ប្លែកៗ គួរឱ្យកត់សម្គាល់ និងមិនអាចប៉ាន់ស្មានបាន មានដូចជា គ្រោះធម្មជាតិ បម្រែបម្រួលអាកាសធាតុ ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ... ) ដែលបាននិងកំពុងគំរាមកំហែងដល់ការរស់នៅរបស់មនុស្ស សត្វលើផែនដី បន្ថែមពីលើសង្គ្រាមរ៉ាំរ៉ៃនៅបណ្តាប្រទេសមួយចំនួន រួមទាំងមានគ្រោះមហន្តរាយដោយការរាតត្បាតនៃវីរុសកូវីដ-១៩ និងមេរោគបំប្លែងថ្មីៗ។ វិបត្តិនៃផលប៉ះពាល់ដោយ ជំងឺកូវីដ-១៩ មិនទាន់បានបញ្ចប់ផង ក៏មានព្រឹត្តិការណ៍ដ៏អាក្រក់ជាច្រើនដែលកើតឡើងជាបន្តបន្ទាប់ នោះគឺការផ្ទុះសង្គ្រាមរវាងប្រទេសដែលនៅជិតខាងគ្នានៅក្នុងទ្វីបអឺរ៉ុប គឺសង្គ្រាមរុស្ស៊ី និងអុយក្រែន បានជះឥទ្ធិពលអវិជ្ជមានធ្វើឱ្យមានវិបត្តិសេដ្ឋកិច្ច និងសង្គមជាសាកល ដែលជាកត្តាជំរុញឱ្យមានលំហូរទេសន្តរប្រវេសន៍។

ឆ្លៀតក្នុងស្ថានភាពដ៏ប្រឈមនេះ ក្រុមទុច្ចរិត និងបណ្តាញរបស់ខ្លួន បានព្យាយាមរកគ្រប់មធ្យោបាយ បង្កើតនូវបទល្មើសថ្មីៗ ព្រមជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យាទំនើប សម្រាប់ទាក់ទាញជនរងគ្រោះ ឱ្យធ្លាក់ចូលក្នុងកលល្បិចទុច្ចរិត ដើម្បីបម្រើមហិច្ឆតារបស់ខ្លួន ដែលបង្កឱ្យមានផលប៉ះពាល់យ៉ាងធំធេងលើជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស។

រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋ ដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ-១៩ និងផលប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមដ៏ធំធេង និងខិតខំការពារសន្តិសុខក្នុងប្រទេស និងក្នុងតំបន់ ខិតខំរកដំណោះស្រាយបញ្ហាដោយទន់ភ្លន់បញ្ចៀសការប្រឈមមុខដាក់គ្នា និងការពារភាពរឹងមាំនៃចំណងសាមគ្គីភាព និងកិច្ចសហការក្នុងតំបន់ ជាក់ស្តែងជោគជ័យនៃការដោះស្រាយបញ្ហាតំបន់ក្នុងពេលដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាប្រធានអាស៊ានក្នុងឆ្នាំ២០២២នេះ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងដ៏ច្រើនសន្ធឹកសន្ធាប់ ក្នុងការដោះស្រាយភាពប្រឈមដែលជះឥទ្ធិពលជាអវិជ្ជមានដល់ជីវភាពប្រជាពលរដ្ឋ និងបង្កភាពរាំងស្ទះដល់ការអនុវត្តសកម្មភាពអភិវឌ្ឍន៍គ្រប់វិស័យ រាជរដ្ឋាភិបាលកម្ពុជា ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសេនាធិការ នៅគ្រប់កម្រិត បានរៀបចំយុទ្ធសាស្ត្រ និងដាក់ចេញនូវវិធានការចម្បងៗជាច្រើន រាប់ទាំងការកសាងច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តនានា ដើម្បីការពារប្រជាពលរដ្ឋពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចនានា។ ក្នុងស្ថានភាពដ៏អាក្រក់នៃភាពប្រឈមនឹងការស្វែងរកការងារនៅក្រៅប្រទេសដោយប្រថុយប្រថាន ក្នុងឋានៈជាពលករមិនស្របច្បាប់ រាជរដ្ឋាភិបាលកម្ពុជា តែងស្វះស្វែងរកដំណោះស្រាយជាមួយប្រទេសពាក់ព័ន្ធ ដើម្បីកាត់បន្ថយភាពរងគ្រោះ និងលើកកម្ពស់សុវត្ថិភាពពលករចំណាកស្រុក ព្រមទាំងដោះស្រាយភាពប្រឈមរបស់ពលករវិលត្រឡប់រាប់សិបម៉ឺននាក់ និងប្រជាពលរដ្ឋ

ក្នុងស្រុកដែលប្រឈមនឹងវិបត្តិកូវីដ-១៩ តាមរយៈការដាក់ចេញនូវគោលនយោបាយសន្តិសុខសង្គម យ៉ាងទូលំទូលាយ ដើម្បីបង្ការទប់ស្កាត់ភាពទ័លច្រក និងប្រថុយប្រថានរបស់ប្រជាពលរដ្ឋ ក្នុងការជឿលើការអូសទាញរបស់មេខ្យល់ ឬឧក្រិដ្ឋជនឱ្យធ្លាក់ក្នុងភាពរងគ្រោះ។

ថ្មីៗនេះ មិនត្រឹមតែប្រជាជនកម្ពុជាទេ តែប្រជាជននៃប្រទេសដទៃក្នុងតំបន់ រហូតដល់ពីបណ្តាប្រទេសធំៗក្នុងពិភពលោក ក៏បានធ្លាក់ក្នុងភាពរងគ្រោះដោយកលល្បិចឧក្រិដ្ឋជន។ បញ្ហាជួញដូរមនុស្ស បានក្លាយជាវិបត្តិសាកល ដែលស្ទើរតែគ្រប់ប្រទេសក្នុងសាកលលោកកំពុងប្រឈម ដោះស្រាយ និងកាន់តែស្មុគ្រស្មាញខ្លាំងឡើង។

ប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឱ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ទាំងទ្រព្យសម្បត្តិ និងកម្លាំងកាយ រហូតដល់ធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរថែមទៀត។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ២. ការបង្ការ ទប់ស្កាត់

### ២.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ២.១.១. ការអប់រំដោយផ្ទាល់

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ សរុបចំនួន **៩.១០៦**លើក មានអ្នកចូលរួមសរុបចំនួន **៥១០.៧៣៦**នាក់ (ធៀបនឹងខែតុលាមានចំនួន **៥២៥.២៧២**នាក់ គឺមានការថយចុះចំនួន **១៤.៥៣៦**នាក់ ស្មើនឹង**២,៧៦៧%** ក្នុងនោះស្ត្រីចំនួន **២១៦.៥១៧**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៨ | ៦៣០ | ៤៣៩ | ៥៨៧ | ២៤១០៨ | ១៣០៤៣ |
| | សរុប ក្រសួង ស្ថាប័ន | ១៨លើក | ៦៣០នាក់ | ៤៣៩នាក់ | ៥៨៧លើក | ២៤.១០៨នាក់ | ១៣.០៤៣នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ៥៣២ | ៣២.៩០៩ | ១៦.៥៦៩ | ១.៤៣៧ | ១២៩.០០៦ | ៣៨.៧២៣ |
| ៣ | ខេត្តបាត់ដំបង | ៨៥៥ | ៣២.៨៤៥ | ១៨.០១៥ | ៦៣២ | ១៩.១៨៦ | ១០.០៦៩ |
| ៤ | ខេត្តពោធិ៍សាត់ | ៤២៦ | ៣៦.១៩៥ | ១៨.៦០២ | ១៥៩ | ៥.៣៧០ | ២.២៨៥ |
| ៥ | ខេត្តសៀមរាប | ៣៦៨ | ៨៣.៣០៧ | ២៤.៩៧០ | ៤៥ | ១.៧២១ | ៨៩៨ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៩៥០ | ១៩.៥០៣ | ១០.២៦៧ | ៥១៣ | ១០.០៤៩ | ៥.១៦១ |
| ៧ | ខេត្តកំពង់ចាម | ២.៥៣៧ | ១០៩.៤៦២ | ៥៥.៣៦០ | ១០ | ២.៤០០ | ១.៤៤៦ |
| ៨ | ខេត្តព្រះសីហនុ | ៣៥ | ៣.៤៦៥ | ១.៦៦៦ | ៤ | ៣០៨ | ១២៦ |
| ៩ | ខេត្តព្រះវិហារ | ៧ | ២១២ | ១៥៩ | ១ | ១.៦៩៦ | ២៩០ |
| ១០ | ខេត្តស្វាយរៀង | | | | ៦៦ | ១.៧៤៥ | ៩២៨ |
| ១១ | ខេត្តប៉ៃលិន | ៧១ | ១.៣៦៩ | ៥៦២ | ២៨ | ១.១១៤ | ៤២៥ |
| ១២ | ខេត្តកោះកុង | | | | ៦៦ | ១.៧៤៥ | ៩២៨ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | ២២៣ | ៩.០១០ | ៤.៥១០ | ៩០ | ៣.០៣៦ | ១.៦៤២ |
| ១៦ | ខេត្តក្រចេះ | ១៥ | ៥៤៣ | ៣៤៥ | | | |
| ១៧ | ខេត្តកែប | | | | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៨ | ១៥៦១ | ១៥៤៦ | ៨ | ២២៣៦ | ៣៤៩ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៣ | ខេត្តបន្ទាយមានជ័យ | ២ | ៥១៣ | ២៣៧ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៦.០២៩លើក | ៣៣០.៤៩៤នាក់ | ១៥២.៨០៨នាក់ | ៣.០៥៩លើក | ១៧៩.៦១២នាក់ | ៦៣.២៧០នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៩.១០៦ លើក | | ចំនួនមនុស្សសរុប ៥១០.៧៣៦ នាក់ | | ចំនួនស្ត្រី ២១៦.៥១៧ នាក់ | |

### ១.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| អង្គការ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
|---|---|---|---|
| អង្គការមូលនិធិអេ២១ (ខេត្តសៀមរាប) | ១១ | ៩០០ | ៥០៥ |
| អង្គការមូលនិធិអេ២១ (ខេត្តបន្ទាយមានជ័យ) | ០១ | ៣០ | ១០ |
| អង្គការដំណក់ទឹក (ខេត្តបន្ទាយមានជ័យ) | ០៥ | ៤៥៥ | ២៧២ |
| សរុប | ១៧ លើក | ១.៣៨៥ នាក់ | ៧៨៧ នាក់ |

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ផ្សព្វផ្សាយតាមរយៈផេកហ្វេសប៊ុក មានអ្នកទស្សនាចំនួន ១.៥៦០នាក់។
- ខេត្តសៀមរាប៖ មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ២០៣លើក។
- ខេត្តត្បូងឃ្មុំ៖ មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ២០៦លើក។
- ខេត្តព្រៃវែង៖ មន្ទីរពត៌មានខេត្ត ផ្សព្វផ្សាយតាមវិទ្យុ ៥០លើក។

### ខ.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមបើកកម្មវិធី បាថកថាចែករំលែកបទពិសោធន៍ ប្រធានបទ ស្តីពីការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា និងធ្វើបទបង្ហាញជូនដល់សិក្ខាកាម ជានាយនគរបាលជាន់ខ្ពស់ ក្នុងវគ្គសុក្រឹតការថ្នាក់ដឹកនាំនគរបាលកម្រិត៣ រួមនិងថ្នាក់ដឹកនាំ អនុប្រធាន គ្រូបង្គោលបណ្ឌិត្យសភានគរបាលកម្ពុជា ចំនួន ១៩៤នាក់ (ស្រី ១៩នាក់) នៅបណ្ឌិត្យសភានគរបាលកម្ពុជា។
- ខេត្តកំពង់ចាម៖
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងវិទ្យុចំនួន ០១លើក ក្រោមប្រធានបទ "ការអន្តរាគមន៍ និងជួយសង្គ្រោះស្ត្រីរងគ្រោះចាញ់បោកមេខ្យល់នាំទៅក្រៅប្រទេស"។
  - មន្ទីរកិច្ចការនារីខេត្ត បានចូលរួមជាវាគ្មិនក្នុងវិទ្យុចំនួន ០១លើក ក្រោមប្រធានបទ "ការយល់ដឹង និងផ្តល់ជំនាញដល់ស្ត្រី ដើម្បីកាត់បន្ថយភាពក្រីក្រ តាមប្រព័ន្ធអនឡាញ"។

### ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- ខេត្តសៀមរាប៖ ចែកខិតប័ណ្ណ ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ៣១០ប័ណ្ណ។
- អង្គការសាម៉ារីតាន់ភឺស (ខេត្តបន្ទាយមានជ័យ)៖ បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន ៨៤៣នាក់ (ស្រី ៣៣៨នាក់) កុមារ ១១៩នាក់ (កុមារី ៥៥នាក់)។

- **អង្គការ IOM** (ខេត្តបន្ទាយមានជ័យ)៖ បានចែកសម្ភារៈដល់ជនទេសន្តរប្រវេសន៍វិលត្រលប់មកកម្ពុជាវិញ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **២៦**នាក់ (ស្រី **១៧**នាក់)។
- **អង្គការសាម៉ារីតាន់ភឺស** (ខេត្តបាត់ដំបង)៖ បានចែកខិត្តប័ណ្ណផ្សព្វផ្សាយ អំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពចំនួន **២.៦០២**នាក់ (ស្រី **១.២០៩**នាក់) កុមារ **៣៧៧**នាក់ (កុមារី **១៦១**នាក់)។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

- **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានធ្វើការចុះអធិការកិច្ចជនបរទេសចំនួន **៤១**សហគ្រាស ពិនិត្យឃើញមានជនបរទេសចំនួន **៧៦**នាក់ (ស្រី **២១**នាក់) ក្នុងនោះអ្នកមានប័ណ្ណនិងសៀវភៅការងារចំនួន **៧៥**នាក់ (ស្រី **២១**នាក់) និងគ្មានប័ណ្ណនិងសៀវភៅការងារ **០១**នាក់។
- **ខេត្តត្បូងឃ្មុំ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ចហត្ថពលកម្មបរទេស និងផ្សព្វផ្សាយ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន **៧៩**សហគ្រាស ក្នុងនោះមានកម្មករ និយោជិតខ្មែរសរុបចំនួន **៤.៩២៩**នាក់ (ស្រី **២.៩៧៧**នាក់) និងហត្ថពលករបរទេសចំនួន **១៩៨**នាក់ (ស្រី **២៥**នាក់)។
- **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ និងជំរុញផ្សព្វផ្សាយការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗពាក់ព័ន្ធវិស័យការងារ នៅតាមរោងចក្រ សហគ្រាសចំនួន **៨០**សហគ្រាស មានកម្មករ និយោជិតសរុបចំនួន **១.៧៥៥**នាក់ (ស្រី **៨៣៩**នាក់) ក្នុងនោះមានកម្មករ និយោជិតបរទេសចំនួន **៣៣**នាក់ (ស្រី **១៦**នាក់)។

### ខ.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន **២៣៧.៧២៦**នាក់ (ស្រី**១០៤.៩៧៧**នាក់) អនីតិជន **៣.៨៣៥**នាក់ (ស្រី **១.៤៦៤**នាក់)៖
  - ស្របច្បាប់ ចំនួន**១៧៩.២២៧**នាក់ (ស្រី**៨១.៥៥៤**នាក់) អនីតិជន**១.២១៦**នាក់ (ស្រី**៤៩៨**នាក់)
  - មិនស្របច្បាប់ចំនួន**៥៧.៨០៦**នាក់(ស្រី**២៣.២២៤**នាក់)អនីតិជន**២.៥១៥**នាក់(ស្រី**៩៣៧**នាក់)
  - ដាច់ការទាក់ទងចំនួន**៦៩៣**នាក់(ស្រី**២៩៩**នាក់)អនីតិជន**១០៤**នាក់(ស្រី**២៩**)។
- **ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត** បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់មកវិញដោយខ្លួនឯង ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន **៧៩.១៦៧**នាក់ (ស្រី **៣៤.១៦៨**នាក់) អនីតិជន **៤១៩**នាក់ (ស្រី **១៥៦**នាក់)។
- **ខេត្តបន្ទាយមានជ័យ៖** កងកម្លាំងស្នងការឈរជើងតាមបន្ទាត់ព្រំដែន (នគរបាល និងយោធា) បានធ្វើការទប់ស្កាត់ពលករធ្វើចំណាក់ស្រុកខុសច្បាប់ នៅតាមបន្ទាត់ព្រំដែន កម្ពុជា-ថៃ បានចំនួន **៤៥**លើក មនុស្សចំនួន **៩១៧**នាក់ (ស្រី **៣២០**នាក់ កុមារ **១១១**នាក់) រួចបានធ្វើកិច្ចសន្យាអប់រំណែនាំកុំអោយចំណាកស្រុកដោយខុសច្បាប់ទៅក្រៅប្រទេសទៀត។

### ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ កែប កំពង់ឆ្នាំង និងខេត្តព្រះសីហនុ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់

អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន **១០៣**គោលដៅ មនុស្សចំនួន **៤៣៣**នាក់ (ស្រី **៣៧៩**នាក់)។

- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ បាត់ដំបង កោះកុង ព្រះវិហារ ឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យ មានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន **២៤**លើក។

**ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំចុះបញ្ជីការរៀបអាពាហ៍ពិពាហ៍ចំនួន **១១៣**នាក់ (ស្រី ០៨នាក់) មាន **១៥**សញ្ជាតិ ក្នុងនោះជនជាតិកូរ៉េខាងត្បូង **៣៧**នាក់ (ស្រី ០៤នាក់) ចិន **២៧**នាក់ អាមេរិក **២៦**នាក់ (ស្រី **០៤**នាក់) បារាំង **០៥**នាក់ កាណាដា **០៥**នាក់ ជប៉ុន **០២**នាក់ អូស្ត្រាលី **០២**នាក់ ម៉ាឡេស៊ី **០២**នាក់ ស៊ុយអែត **០១**នាក់ បែលហ្ស៊ិក **០១**នាក់ ឆែក **០១**នាក់ អង់គ្លេស **០១**នាក់ សឹង្ហបុរី **០១**នាក់ វៀតណាម **០១**នាក់ និងអាឡឺម៉ង់ **០១**នាក់ បានវាយតំលៃបញ្ជូនឱ្យក្រុមការងារប្រេកចេញចូលតែមួយចំនួន **១០៣**នាក់។ បានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ រៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូង ចំនួន **០៦**នាក់ (ស្រី)។

**ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍ចំនួន **១.១៣៣**នាក់ ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

**គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **១២**ករណី(ធៀបនឹងខែតុលា មានចំនួន **២៣**ករណី ថយចុះចំនួន **១១**ករណី) ស្មើនឹង**៤៧,៨២%** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង បានចំនួន **១៤**នាក់(ស្រី **០៤**នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន **០៤**នាក់ និងជនជាតិចិន **០១**នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **៣៦**នាក់ (ស្រី **២៦**នាក់) មានៈ អាយុក្រោម១៥ឆ្នាំ **១៤**នាក់(ស្រី) អាយុ ១៥-១៧ឆ្នាំ **០៣**នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង **១៩**នាក់(ស្រី **០៩**នាក់) ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **១៦**នាក់ (ស្រី **០៨**នាក់) និងគ្រួសារចំនួន **២០**នាក់ (ស្រី **១៨**នាក់)។ ក្នុងនោះបែកជា៖ ភាគរយ

### ១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន **០៣**ករណី/**០៧**ករណី (ថយចុះ **០៤**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **០៤**នាក់(ស្រី **០១**នាក់) ជនជាតិចិន **០១**នាក់។ សង្គ្រោះជនរងគ្រោះចំនួន ចំនួន**១៨**នាក់(ស្រី **០៨**នាក់) មាន: អាយុក្រោម១៥ឆ្នាំ **០២**នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង **១៦**នាក់(ស្រី **០៦**នាក់) ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **១៦**នាក់(ស្រី **០៨**នាក់) និងឱ្យគ្រួសារ **០២**នាក់។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ១៤ | ០២ | |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០២ | ០១ | ចិន១ |
| -អំពើអូសទាញពេស្យាចារកុមារ | ០១ | ០២ | ០១ | |
| *សរុប* | *០៣ ករណី* | *១៨ នាក់* | *០៤ នាក់* | *០១ នាក់* |

### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **០៩**ករណី/**១៦**ករណី (ថយចុះ**០៧**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **១០**នាក់(ស្រី **០៣**នាក់)ជនសង្ស័យជាអនីតិជន **០៤**នាក់។ សង្គ្រោះជនរងគ្រោះចំនួន **១៨**នាក់ មាន: អាយុក្រោម១៥ឆ្នាំ**១២**នាក់ (ស្រី) អាយុ១៥-១៧ឆ្នាំ**០៣**នាក់(ស្រី) និងអាយុ១៨ឆ្នាំឡើង**០៣**នាក់(ស្រី) ប្រគល់ឱ្យគ្រួសារ**១៨**នាក់(ស្រី)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -សញ្ចារកម្មមានអនីតិជន | ០១ | ០៧ | ០២ |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០១ | ០៣ | ០១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ | ០៥ |
| -អំពើអាសប្រចាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០៣ | ០២ (អនី.០៤) |
| *សរុប* | *០៩ ករណី* | *១៨ នាក់* | *១០ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន **៩៨៤**នាក់(ស្ត្រី **១៤៧**នាក់) កុមារ **៦៥**នាក់ (កុមារី **៦០**នាក់)សកម្មភាពមានដូចជា៖
- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ**
  - បានទទួលចំនួន **២៣**នាក់ (ស្ត្រី **២០**នាក់) (កុមារី **០២**នាក់) មកពីប្រទេសចិន **២២**នាក់ និង ម៉ាឡេស៊ី **០១**នាក់ ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធម្មនុញ្ញ:/បង្ខំ **១៨**នាក់ និងងាយរងគ្រោះ **០៥**នាក់

បន្ទាប់ពីបានសម្ភាសន៍កំណត់អត្តសញ្ញាណបឋម ១៨នាក់ (ស្ត្រី ១៧នាក់) រួចបញ្ជូនទៅទទួលសេវាបន្តអង្គការដៃគូ។

- បានទទួលពីនគរបាលមានសមត្ថកិច្ចនៅក្នុងស្រុកចំនួន ១៤នាក់ (ស្ត្រី០៦នាក់) ជាករណីងាយរងគ្រោះដោយអំពើជួញដូរមនុស្ស។

- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពីប្រទេសថៃចំនួន ៩៤៧នាក់ (ស្ត្រី ១២១នាក់)កុមារ ៦៣នាក់ (កុមារី ៥៨នាក់) បានសម្ភាសកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះគ្មាន ជនងាយរងគ្រោះចំនួន ៨៦នាក់ (ស្ត្រី ២៤នាក់) កុមារ ១៣នាក់ (កុមារី ០៣នាក់) និងកុមារមិនមានមនុស្សអមដំណើរមកជាមួយ និងផ្តល់ការស្នាក់នៅរយៈពេលខ្លី ក្នុងមណ្ឌលសំចតមុនពេលបញ្ជូនទៅទទួលសេវាស្នាក់នៅបន្ត នៅអង្គការដៃគូ និងសហគមន៍វិញ។

- អគ្គស្នងការដ្ឋាននគរបាលជាតិ
  - **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់ពីប្រទេសចិន ចំនួន ០៤នាក់(ស្រី)។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈទៅចិន ០៤នាក់(ស្រី) អនីតិជន ០២នាក់។
  - **ខេត្តបន្ទាយមានជ័យ៖** ស្នងការនគរបាលខេត្ត ពលករចូលតាមច្រកអូរបីជាន់ ច្រកបឹងត្រកួន ច្រកចំបក់ និងច្រកអន្តរជាតិប៉ោតប៉ែត ចំនួន ៤៣លើក មនុស្សចំនួន ៨៧៧នាក់ (ស្រី ៣៣២នាក់) អនីតិជន ១១៣នាក់ (ស្រី ៥២នាក់)។
  - **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញចំនួន ០៦លើក មនុស្សចំនួន ១២នាក់ (ស្រី ០៤នាក់)។
  - **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរ ដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាមចំនួន ០៦លើក មនុស្សចំនួន ១២នាក់ (ស្រី ០៤នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ០៩នាក់ (ស្ត្រី ០២នាក់) កុមារ ០៧នាក់ (កុមារី ០៤នាក់) ក្នុងនោះបានមកពីអង្គការក្តីសង្ឃឹមនិងយុត្តិធម៌ ០១នាក់ អង្គការមេត្រីអន្តរជាតិ ០៦នាក់ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ ០២នាក់ មានករណីរំលោភបំពានផ្លូវភេទ ០៧នាក់ និងជួញដូរកម្លាំងពលកម្ម ០២នាក់។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញចំនួន ០៥នាក់ (ស្ត្រី ០១នាក់) កុមារ ០៤នាក់ (កុមារី ០៣នាក់) មានករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ០១នាក់ និងកេងកម្លាំងពលកម្ម ០៤នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយអង្គការ ASEAN-ACT និងអង្គការបេសកម្មយុត្តិធម៌អន្តរជាតិ រៀបចំវគ្គបណ្តុះបណ្តាលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់មន្ត្រីអាជ្ញាធរមូលដ្ឋាន ដើម្បីផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុងខេត្តព្រះវិហារ និងខេត្តត្បូងឃ្មុំ ។ | ០២ | ៩៨ | ២៣ |
| **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានសហការជាមួយអង្គការ Aple បើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ យន្តការណ៍រាយការណ៍សកល និងការប្រយុទ្ធប្រឆាំងសម្ភារៈរំលោភបំពានផ្លូវភេទកុមារ(នៅសណ្ឋាគារហាយយ៉ាតរីជិនស៊ីភ្នំពេញ)។ | ០១ | ៤០ | ០៩ |
| **ខេត្តសៀមរាបៈ** | | | |
| - លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការមូលនិធិអន្តរជាតិហាការ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ក្រុមការងារប្រយុទ្ធប្រឆាំអំពើជួញដូរមនុស្សស្រុកស្រីស្នំ។ | ០១ | ២៨ | ១២ |
| - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ បានធ្វើការបណ្តុះបណ្តាលគ្រូបង្គោល នៅតាមវិទ្យាល័យ អនុវិទ្យាល័យ នៅក្នុងក្រុងសៀមរាប ស្រុកបន្ទាយស្រី ស្រុកអង្គរធំ ស្រុកអង្គរជុំ និងស្រុកស្រីស្នំ ស្តីពីការទប់ស្កាត់ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទតាមអនឡាញ។ | ០១ | ៤៤ | ៣៩ |
| **ខេត្តត្បូងឃ្មុំៈ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយក្រសួងកិច្ចការនារី រៀបចំបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពី"**ការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន**" ។ | ០១ | ៥៧ | ៤១ |
| **ខេត្តព្រៃវែងៈ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើកវគ្គបណ្តុះបណ្តាល ស្តីពី"**យន្តការក្នុងការទទួលពាក្យបណ្តឹង និងគោលការណ៍ណែនាំសម្រាប់អ្នកដោះស្រាយវិវាទពលករ**" ។ | ០១ | ២០ | ០០ |
| **អង្គការសាម៉ារីតាន់ភឺស (ខេត្តបាត់ដំបង)ៈ** | | | |
| - បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការកេងប្រវ័ញ្ចកុមារតាមប្រព័ន្ធអនឡាញ ដល់ក្រុមបណ្តាញការពារសហគមន៍ ៤ឃុំ គោលដៅក្នុងស្រុកសង្កែ។ | ០១ | ៨៨ | ៤៥ |
| - បានសហការជាមួយ គ.ក.ស.ក និង គ.ក.ន.ក បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្សទៅដល់សហគមន៍នៅក្នុងភូមកំពុងចម្លង។ | ០១ | ១០៤ | ៤៥ |

| | | | |
|---|---|---|---|
| - បានសហការជាមួយ គ.ក.ស.ក និង គ.ក.ន.ក មេភូមិ បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ទៅដល់ឃុំបឹងរាំង និងឃុំអូរដា។ | ០១ | ១១៦ | ០០ |
| - បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ដល់ គ.ក.ស.ក និង គ.ក.ន.ក ។ | ០១ | ១៩ | ១១ |
| - បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ទៅកាន់យុវជន។ | ០១ | ១០ | ០៦ |
| - បានសហការជាមួយ គ.ក.ស.ក និង គ.ក.ន.ក បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ទៅកាន់សហគមន៍ដែលរស់នៅក្នុងភូមិស្វាយស ឃុំកំរៀង។ | ០១ | ៤៧ | ៣៦ |
| - បានសហការជាមួយ គ.ក.ស.ក និង គ.ក.ន.ក បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ទៅកាន់សហគមន៍ដែលរស់នៅក្នុងភូមិតាសែន ឃុំត្រាង។ | ០១ | ៥៦ | ៤៤ |
| - បានសហការជាមួយ គ.ក.ស.ក និង គ.ក.ន.ក បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ទៅកាន់សហគមន៍ដែលរស់នៅក្នុងភូមិអូរអន្លក ឃុំតាសែន។ | ០១ | ២៥ | ១៧ |
| - បានសហការជាមួយ គ.ក.ស.ក និង គ.ក.ន.ក បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការទប់ស្កាត់ការជួញដូរមនុស្ស ទៅកាន់សហគមន៍ដែលរស់នៅក្នុងភូមិដូង ឃុំបឹងរាំង។ | ០១ | ៤៤ | ២៩ |
| **សរុប** | **១៦ វគ្គ** | **៧៩៦ នាក់** | **៣៥៧ នាក់** |

### ក.២. សិក្ខាសាលា

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការទទួលបានសេវាគាំទ្រសម្រាប់កុមាររងគ្រោះ ក្នុងដំណើរនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ មានសិក្ខាកាមចូលរួមចំនួន **៣២**នាក់ (ស្រី **១៥**នាក់) នៅសណ្ឋាគារ កាំបូឌីយ៉ាណា ។
- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖**
  - បានរៀបចំកិច្ចពិភាក្សានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការបង្កើតផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្ស (២០២២-២០២៣) ក្រោមកិច្ចសហការគាំទ្រដោយអង្គការ Winrock Asian Act និងIOM ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានសិក្ខាចូលរួមសរុប **១០២**នាក់ នៅភោជនីយដ្ឋានទន្លេបាសាក់។
  - បានសហការជាមួយអង្គការ IJM រៀបចំសិក្ខាសាលា ស្តីពីបកគំហើញ នៃការសិក្សាស្រាវជ្រាវលើការឆ្លើយតបនៃប្រព័ន្ធយុត្តិធម៌សាធារណៈ លើការងារប្រយុទ្ធប្រឆាំងនៃអំពើជួញដូរពលកម្មនៅកម្ពុជា ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានសិក្ខាចូលរួមចំនួន **៥៤**នាក់ (ស្រី **១៧**នាក់) នៅភោជនីយដ្ឋានទន្លេបាសាក់។

## ២. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ២.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

  លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន អញ្ជើញ៖

  - ដឹកនាំកិច្ចប្រជុំរបាយការណ៍រយៈពេល០៩ខែ ឆ្នាំ២០២២ ជាមួយរាជធានី-ខេត្ត ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន **៧០**នាក់ នៅទីស្ដីការក្រសួងមហាផ្ទៃ។
  - ដឹកនាំកិច្ចប្រជុំពិភាក្សា ត្រៀមរៀបចំកម្មវិធីទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ ២០២២ នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាំកិច្ចប្រជុំផ្ដល់ធាតុចូល ស្ដីពីសំណើសុំរាជរដ្ឋាភិបាលកម្ពុជា ផ្ដល់ការបំភ្លឺអំពីករណីជួញដូរមនុស្សនៅកម្ពុជា អ្នកចូលរួមចំនួន **២៩**នាក់ (ស្រី **០៩**នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្ដីអំពីការបន្តការងារជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីពិភាក្សាលទ្ធផលសិក្ខាសាលា ស្ដីពីតុលាការដែលយកចិត្តទុកដាក់លើជនរងគ្រោះ VSC និងសំណុំទិន្នន័យដែលប្រព្រឹត្តទៅកាលពីថ្ងៃទី ២០-២២ ខែកញ្ញា ឆ្នាំ២០២២។

- **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** លោកប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានចូលរួមកិច្ចប្រជុំ ឧត្តមមន្ត្រីទទួលបន្ទុកកិច្ចការពលកម្ម និងរៀបចំការដាក់ដំណើរការគម្រោងនៃការដោះស្រាយ ការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងការនេសាទក្នុងអាស៊ាន ដែលប្រារព្ធឡើងនៅទីក្រុងបាលី ប្រទេសឥណ្ឌូណេស៊ី។

### ២.២.ការទទួលជួបពិភាក្សាការងារ

- **ខេត្តបន្ទាយមានជ័យ៖** លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារ បានជួបពិភាក្សាការងារជាមួយអង្គការណូមីណែតវើកកម្ពុជា ទាក់ទងនឹងស្ថានភាពជួញដូរស្ត្រីក្នុងខេត្តបន្ទាយមានជ័យ។

### ២.៣.ការងារទស្សនកិច្ច

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាង អង្គការ IOM, UNFPA, WHO និង UNICEF តំណាងស្ថានទូតជប៉ុន ដើម្បីធ្វើទស្សនកិច្ចទៅកាន់ច្រកទ្វារទ្វេភាគី កម្ពុជា-ថៃ តំបន់បឹងត្រកួន ដើម្បីពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងក្រោមជំនួយនៃរាជរដ្ឋាភិបាលជប៉ុន និងដើម្បីពិនិត្យមើលការគ្រប់គ្រងលំហូរនៃប្រជាពលរដ្ឋខ្មែរ ឆ្លងកាត់ព្រំដែន។
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន ដឹកនាំប្រតិភូ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តំណាងអង្គការ IOM, UNDP, UNFPA, WHO, UNICEF និងតំណាងស្ថានទូតជប៉ុន ដើម្បីធ្វើទស្សនកិច្ច និងពិនិត្យសកម្មភាព ក្រុមការងារនៅមណ្ឌលទទួលពលករកំរៀង ស្ថិតនៅក្នុងឃុំកំរៀង ស្រុកកំរៀង ខេត្តបាត់ដំបង។

### គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៣២**លើក មានអ្នកចូលរួមសរុប **១៩៥**នាក់ (ស្រី **៦៨**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១៩**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **០៦**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **០៧**លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការផ្ញើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឱ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

**V. ទិសដៅខែធ្នូ ឆ្នាំ ២០២២**

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្រួលសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.សុក្រ ១៣កើត..ខែមាឃ..ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី.៣...ខែ.កុម្ភៈ.ឆ្នាំ២០២៣

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៣២លើក) មនុស្សចំនួន ១៩៥នាក់ (ស្រី ៦៨នាក់)

| ស្ថាប័ន<br>សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>(គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>- បានអញ្ជើញចូលរួមជាអធិបតីភាព ក្នុងសិក្ខាសាលាពិគ្រោះយោបល់ ស្ដីពីការរៀបចំបង្កើតផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២២-២០២៣) នៅសាលប្រជុំ Kampus។<br>- បានអញ្ជើញជាអធិបតី ក្នុងកម្មវិធីសិក្ខាសាលាប្រចាំឆមាស នៃសមាជិកអង្គការសម្ព័ន្ធចាប់ដៃលើកទី៣៦ ក្រោមប្រធានបទ «**កិច្ចសហការប្រកបដោយភាពស្វាសហាប់**» នៅសាលប្រជុំនៃមជ្ឈមណ្ឌល DK។<br>- បានអញ្ជើញជាអធិបតី ក្នុងសិក្ខាសាលាចែករំលែក ស្ដីពីលទ្ធផលវាយតម្លៃពីប្រសិទ្ធភាពគម្រោង «**ការផ្ដល់សេវាកម្មគ្រប់ជ្រុងជ្រោយ ជួយដល់អ្នករស់រានមានជីវិត ដោយសារការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងអំពើរំលោភបំពាននានា**» ដែលរៀបចំដោយ អង្គការហាហ្គាអូស្ត្រាលី។<br>- បានអញ្ជើញចូលរួមក្នុងកម្មវិធី «ចុះហត្ថលេខាលើក្រមសីលធម៌ សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជា និងពិធីសម្ពោធផ្សព្វផ្សាយ ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធវាយតម្លៃសាកល្បង» រៀបចំដោយសមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារសាន់វ៉េ។<br>- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីសុំការពិនិត្យ-សម្រេចទៅលើខ្លឹមសារ MOU រវាង គ.ជ.ប.ជ និងអង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំកម្ពុជា ស្ដីពីការទប់ស្កាត់ការរំលោភ បំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ២៨ច្បាប់ លិខិតចូល ២២ច្បាប់។<br>- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១៥ច្បាប់ លិខិតចូល ១៦ច្បាប់។<br>- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។ |

- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែវិច្ឆិកា ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៥២ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។
- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន១២សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- លោកប្រធានក្រុមការងារបង្ការ ទប់ស្កាត់
  - បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យសេចក្តីព្រាង ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជនទេសន្តរប្រវេសន៍ ថ្នាក់ក្រោមជាតិខេត្តបាត់ដំបង នៅសាលប្រជុំរបស់មន្ទីរសុខាភិបាល ខេត្តបាត់ដំបង។
  - បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យសេចក្តីព្រាង ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជនទេសន្តរប្រវេសន៍ ថ្នាក់ក្រោមជាតិខេត្តបន្ទាយមានជ័យ សាលប្រជុំរបស់មន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក
  - បានអញ្ជើញចូលរួមសម្របសម្រួល ដល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាល និងប្រជាការពារ ស្តីពីការផ្តល់ប្រឹក្សាពាក់ព័ន្ធ និងអំពើហិង្សាការរំលោភបំពានគ្រប់ទម្រង់ ខេត្តកំពង់ធំ។
  - បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យសេចក្តីព្រាង ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជនទេសន្តរប្រវេសន៍ ថ្នាក់ក្រោមជាតិខេត្តបន្ទាយមានជ័យ សាលប្រជុំរបស់មន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ។

| | |
|---|---|
| | - លោកប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ<br>○ បានចូលរួមពិធីផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រ ឆ្នាំ២០២២ដល់២០២៥ នៃអង្គការឆាលហ្វានកម្ពុជា ពិធីដាក់ឱ្យដំណើរការគម្រោងសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារីភ្នំពេញ។<br>○ បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យសេចក្តីព្រាង ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជនទេសន្តរប្រវេសន៍ ថ្នាក់ក្រោមជាតិខេត្តបាត់ដំបង នៅសាលប្រជុំរបស់មន្ទីរសុខាភិបាល ខេត្តបាត់ដំបង។<br>○ បានចូលរួមប្រជុំតាមប្រព័ន្ធអនឡាញ កិច្ចប្រជុំនេះធ្វើឡើងជាមួយភាគីថៃ និងខាងកម្ពុជា ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**<br>- លោកប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួមអមដំណើរ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ឡាំ ជា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដើម្បីសុំការពិនិត្យ-សម្រេចទៅលើខ្លឹមសារ MOU រវាង គ.ជ.ប.ជ និងអង្គការដែនដីមនុស្សហូឡង់ដ៏ប្រចាំកម្ពុជា ស្តីពីការទប់ស្កាត់ការរំលោភ បំពានផ្លូវភេទ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ អគ្គលេខាធិការរងទទួលបន្ទុក<br>○ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ស្តីពីវឌ្ឍនភាព ការងារ ឆ្នាំ២០២១-២០២២ និងលើកទិសដៅការងារបន្ត របស់ក្រុមការងារ SOMTC កម្ពុជា ក្រោមអធិបតីភាពឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារ ឧក្រិដ្ឋកម្មឆ្លងដែនកម្ពុជា។<br>○ បានអញ្ជើញចូលរួមក្នុងរួមសិក្ខាសាលា វាយតម្លៃគម្រោង "ផ្តល់សិទ្ធិអំណាចជូនស្ត្រី និងក្មេងស្រី តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីទប់ស្កាត់អំពើហឹង្សាលើស្ត្រី ពលករចំណាកស្រុក នៅភោជនីដ្ឋានទន្លេបាសាក់២។<br>- លោកស្រី អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពហុភាគី ស្តីពីយន្តការបញ្ជូនឆ្លងដែន សម្រាប់មហាអនុតំបន់មេគង្គ នៅសណ្ឋាគារ អាម៉ារីរ៉ីធើហ្គេត។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យសេចក្តីព្រាង ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជនទេសន្តរប្រវេសន៍ ថ្នាក់ក្រោមជាតិខេត្តបាត់ដំបង នៅសាលប្រជុំរបស់មន្ទីរសុខាភិបាល ខេត្តបាត់ដំបង។<br>- បានចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យសេចក្តីព្រាង ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសជនទេសន្តរប្រវេសន៍ ថ្នាក់ក្រោមជាតិខេត្តបន្ទាយមានជ័យ សាលប្រជុំរបស់មន្ទីរសុខាភិបាល ខេត្តបន្ទាយមានជ័យ។ |

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី៥ របស់គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | - បានចូលរួមកិច្ចប្រជុំពិភាក្សាលក្ខណៈបច្ចេកទេសពង្រាងផែនការសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះ រវាងអគ្គនាយកដ្ឋាន ស្ថិតនៅក្រោមអគ្គនាយកសេវាសង្គមកិច្ច ជាមួយអង្គការដៃគូ។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សាផ្តល់ការឆ្លើយតប ស្តីពីសំណើសុំរាជរដ្ឋាភិបាលកម្ពុជាផ្តល់ការបំភ្លឺអំពីករណីជួញដូរមនុស្សនៅកម្ពុជា រៀបចំដោយ គ.ជ.ប.ជ។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ពហុភាគី លើយន្តការបញ្ជូនឆ្លងដែន នៃប្រទេសមហាអនុតំបន់មេគង្គ នៅទីក្រុងបាងកកប្រទេសថៃ ដែលសហការរៀបចំក្រសួងកិច្ចការនារី និងអង្គការ UNDP។<br>- បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសដើម្បីពិនិត្យ និងពិភាក្សាលើការបែងចែកអនុសាសន៍គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ។<br>- បានចូលរួមសិក្ខាសាលាវាយតម្លៃគម្រោង ផ្តល់សិទ្ធិអំណាចជូនស្ត្រី និងក្មេងស្រីតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីទប់ស្កាត់អំពើហឹង្សាលើស្ត្រីពលករចំណាកស្រុក រៀបចំដោយអង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។<br>- បានចូលរួមសិក្ខាសាលា ស្តីពីបទបង្ហាញលទ្ធផលដែលបានរកឃើញពីការពិភាក្សាលើការឆ្លើយតប នៃប្រព័ន្ធយុត្តិធម៌សាធារណៈទៅលើការងារប្រយុទ្ធប្រឆាំងលើបទល្មើសជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន រៀបចំដោយ គ.ជ.ប.ជ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ០៧លើក អ្នកចូលរួមសរុបចំនួន ១៩៥នាក់ (ស្រី ៦៨នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកកិច្ចប្រជុំបូកសរុបលទ្ធការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០២២ ចំនួន០១លើក អ្នកចូលរួមចំនួន២៦នាក់ ស្រី២០នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ បានចំនួន ០៥លើក អ្នកចូលរួមចំនួន១៥៧នាក់ ស្រី៣៩នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - បានរៀបកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន១២នាក់ ស្រី០៩នាក់។ |